# កិច្ចព្រមព្រៀង
## ស្តីពីការទិញ-លក់ ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្មនៅតំបន់ព្រំដែន
## រវាង
## រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
## និង
## រដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងក្រោម ហៅកាត់ថា " ភាគីហត្ថលេខី "

ឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខា នៅថ្ងៃទី ២៤ ខែមិនា ឆ្នាំ ១៩៩៨

ក្នុងគោលបំណងបង្កើនទំនាក់ទំនងមិត្តភាពរវាងប្រទេសជិតខាងទាំងពីរ ជំរុញសកម្មភាពទិញ-លក់ ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្មនៅតាមតំបន់ព្រំដែន ចូលរួមប្រាស្រ័យ លើកកំពស់ជីវភាពរស់នៅ របស់ ប្រជាជននៅតាមព្រំដែន និង អភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសនិមួយៗ ដោយឈរលើគោលការណ៍ស្មើភាព និង មានផលប្រយោជន៍ទៅវិញទៅមក

## បានព្រមព្រៀងគ្នាដូចខាងក្រោម :

### ប្រការ ១ :

និយមន័យ

១- តំបន់ព្រំដែន : រួមមានបណ្តាឃុំ-សង្កាត់ ទីរួមស្រុក ដែលមានព្រំប្រទល់រដ្ឋបាលតភ្ជាប់នឹង ផ្លូវព្រំដែនជាតិ លើដីគោក រវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម ។

២- ពាណិជ្ជករ : រួមមានបណ្តាក្រុមហ៊ុនស្ថិតក្រោមសមាសភាពសេដ្ឋកិច្ចនានា គ្រួសារនានាដែលធ្វើអាជីវកម្ម នៅតំបន់ព្រំដែន ប្រជាជននៅតំបន់ព្រំដែននៃប្រទេសទាំងពីរ ។

៣- ប្រជាជននៅតំបន់ព្រំដែនរួមមាន :

- ពលរដ្ឋកម្ពុជា ឬ ពលរដ្ឋវៀតណាម ដែលមានបណ្ណ័សំគាល់គ្រួសារជាអចិន្ត្រៃយ៍ នៅតំបន់ព្រំដែន។

- អ្នកដែលមានលិខិតអនុញ្ញាតពីអង្គភាពនគរបាលខេត្តព្រំដែន អោយស្នាក់នៅក្នុងតំបន់ព្រំដែន។

- អ្នកដែលស្ថិតក្នុងអង្គភាព អង្គការចាត់តាំងកងប្រដាប់អាវុធ មានទីស្នាក់ការធ្វើការជា អចិន្ត្រៃយ៍នៅតំបន់ព្រំដែន ។

៤- ភាគីទាំងពីរ : មានរដ្ឋាភិបាល និង រដ្ឋអំណាចមូលដ្ឋាន តំបន់ព្រំដែន នៃប្រទេសនិមួយៗ ។

**ប្រការ ២ :** ការទិញ-លក់ ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្មនៅតំបន់ព្រំដែន ដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះ គឺជាសកម្មភាពទិញ-លក់ ផ្លាស់ប្តូរទំនិញនិងសេវាពាណិជ្ជកម្មរវាងពាណិជ្ជករកម្ពុជា និង ពាណិជ្ជករវៀតណាម ដែលមានការអនុញ្ញាតឱ្យធ្វើសកម្មភាពអាជីវកម្មតាមការកំណត់ច្បាប់ នៃប្រទេស និមួយៗ ។

**ប្រការ ៣ :** ការទិញ-លក់ផ្លាស់ប្តូរទំនិញ និង សេវាពាណិជ្ជកម្មនៅតំបន់ព្រំដែន ត្រូវអនុវត្តឆ្លងកាត់តាមបណ្តាមាត់ច្រក ដែលភាគីទាំងពីរបានឯកភាពគ្នាក្នុងខេត្តវៀតណាម ចំនួន០៩: កុងទុម យ៉ាឡៃ ដាក់ឡាក់ បិញភឿក តៃនិញ ឡុងអាន ដុងថាប អានយ៉ាង និង គៀនយ៉ាង និង ខេត្ត-ក្រុងនៃប្រទេសកម្ពុជាចំនួន ១០: រតនគីរី មណ្ឌលគីរី ក្រចេះ កំពង់ចាម ស្វាយរៀង ព្រៃវែង កណ្តាល កំពត តាកែវ និង ក្រុងកែប ។

**ប្រការ ៤ :** ទំនិញទិញ-លក់ ផ្លាស់ប្តូរទំនិញនិងសេវាពាណិជ្ជកម្មនៅតំបន់ព្រំដែនរួមមាន បណ្តាមុខទំនិញដែលគ្មានស្ថិតក្នុងតារាងរាយមុខទំនិញហាម នាំចេញ-នាំចូលនៃប្រទេសនិមួយៗ

( តារាងរាយមុខទំនិញ ហាមឃាត់មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ០១ និង ០២ ) ។ ក្នុងករណីមានការកែប្រែណាមួយលើមុខទំនិញហាមឃាត់ភាគីទាំងពីរនឹងជូនដំណឹងគ្នាទៅវិញទៅមកភ្លាម មុនពេលសេចក្តីសំរេចចិត្តថ្មី ចូលជាធរមាន ។

**ប្រការ ៥ :** ភាគីហត្ថលេខី ត្រូវបង្កលក្ខណៈងាយស្រួលដល់ប្រជាជននៅតាមព្រំដែនត្រូវអនុញ្ញាតឱ្យទិញ-លក់ផ្លាស់ប្តូរទំនិញនិងសេវាពាណិជ្ជកម្មជាចាំបាច់សំរាប់បំរើក្នុងការផលិតជីវភាពរស់នៅ និងគោរពតាមច្បាប់នៃប្រទេសនិមួយៗ។

**ប្រការ ៦ :** ១- ការទូទាត់ក្នុងការទិញ-លក់ ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្មនៅតំបន់ព្រំដែនរវាង ប្រទេសទាំងពីរ ត្រូវអនុវត្តជារូបិយបណ្ណ័ ដែលអាចផ្លាស់ប្តូរបាន ឬ ជាប្រាក់ដុងវៀតណាម ឬ ប្រាក់រៀលកម្ពុជា ។

២-បែបផែនទូទាត់អាស្រ័យដោយភាគីអ្នកលក់ និងភាគីអ្នកទិញទំនិញនៅតាមតំបន់ព្រំដែន ព្រមព្រៀងគ្នា ។

**ប្រការ ៧ :** ភាគីហត្ថលេខី ត្រូវលើកទឹកចិត្ត នឹងបង្កលក្ខណៈងាយស្រួល ជំរុញសកម្មភាពទិញ-លក់ផ្លាស់ប្តូរទំនិញ សេវាពាណិជ្ជកម្ម នៅតំបន់ព្រំដែនឱ្យមានការអភិវឌ្ឍន៏ជាលំដាប់ ដោយមានវិធានការណ៏ទប់ស្កាត់អំពើរត់ពន្ធនិងក្លែងបន្លំក្នុងវិស័យពាណិជ្ជកម្ម សមស្របតាមច្បាប់ នៃប្រទេសនិមួយ ៗ ។

**ប្រការ ៨ :** ១- ភាគីហត្ថលេខី ព្រមព្រៀងអនុវត្តរាល់វិធានការណ៏សំដៅបង្កើន ការគ្រប់គ្រងគុណភាព ទំនិញទិញ-លក់ ផ្លាស់ប្តូរទំនិញ នៅតំបន់ព្រំដែន ដើម្បីធានាផលប្រយោជន៏របស់អ្នកប្រើប្រាស់ ប្រឆាំងទប់ស្កាត់ ទំនិញក្លែងក្លាយ និង ទំនិញអន់គុណភាព ។

២- អាជីវករនៅតាមតំបន់ព្រំដែន ត្រូវគោរពបទបញ្ញត្តិ ស្តីពីការត្រួតពិនិត្យគុណភាពទំនិញ និងពិនិត្យភូតគាមអនាម័យ លើសត្វទូទៅ និងរុក្ខជាតិ ហើយត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ នៃប្រទេសនីមួយៗ លើគុណភាពទំនិញ ដែលខ្លួនធ្វើអាជីវកម្ម ។

**ប្រការ ៩ :** ភាគីហត្ថលេខី ត្រូវបង្កលក្ខណៈងាយស្រួលអោយអាជ្ញាធររបស់ខ្លួន ដំណើរការរាល់សកម្មភាព ជំរុញពាណិជ្ជកម្ម ទិញ-លក់ ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្ម នៅតំបន់ព្រំដែន ដូចជា : ការបើកផ្សារណាត់ ការតាំងពិពណ៌ពាណិជ្ជកម្ម ការបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្ម ទេសចរណ៍ សេវាកម្ម និង វិនិយោគ ។

**ប្រការ១០ :** ដើម្បីធានាការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ភាគីហត្ថលេខីបានព្រមព្រៀងគ្នា និងផ្ទេរសិទ្ធិអនុញ្ញាតឱ្យ អាជ្ញាធរមូលដ្ឋាន ថ្នាក់ខេត្ត នៃភាគីនីមួយៗ ចូលរួមដោះស្រាយរាល់បញ្ហា ដែលកើតមានឡើងចេញពីសកម្មភាពពាណិជ្ជកម្ម តាមព្រំដែន ។

**ប្រការ១១ :** បន្ទាប់ពីកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា ភាគីនីមួយៗត្រូវផ្សព្វផ្សាយនិងធ្វើលិខិតណែនាំអនុវត្តកិច្ចព្រមព្រៀងនេះ ដល់ស្ថាប័នពាក់ព័ន្ធហើយជូនដំណឹងដល់ភាគីម្ខាងទៀត ដើម្បី សហការអនុវត្ត ។

**ប្រការ១២ :** ភាគីហត្ថលេខី បានព្រមព្រៀងគ្នាលើរាល់បញ្ហាផ្សេងៗ ដែលពុំបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តតាមប្រការនានា នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលបានចុះហត្ថលេខា រវាង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយម វៀតណាម ចុះថ្ងៃទី ២៤ ខែមិនា ឆ្នាំ១៩៩៨ ។

**ប្រការ១៣ :** រាល់ទំនាស់ដែលកើតឡើងដោយថាហេតុ លើការបកស្រាយកិច្ចព្រមព្រៀងនេះ ក្នុងដំណើរការ អនុវត្តត្រូវចចារគ្នា នឹងដោះស្រាយតាមរយៈតំណាងមានសមត្ថកិច្ច របស់ក្រសួងពាណិជ្ជកម្ម នៃភាគីទាំងពីរ ។

**ប្រការ១៤ :** ក្នុងសុពលភាព នៃកិច្ចព្រមព្រៀង បើភាគីណាមួយ នៃភាគីចុះកិច្ចព្រមព្រៀងទាំងពីរមានបំណងបំពេញបន្ថែម ឬកែសម្រួលប្រការនានាដែលបានចុះហត្ថលេខាត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ។ ក្នុងរយៈពេល ០៣ ខែគិតចាប់ពីថ្ងៃទទួលសំណើភាគីទទួលនោះ

ត្រូវឆ្លើយតបតាមផ្លូវការជាលាយលក្ខណ៍អក្សរវិញ ។ ការកែប្រែ ឬ បំពេញបន្ថែម ដែលភាគីទាំងពីរបានឯកភាពគ្នាត្រូវបានចាត់ទុកថា ជាចំណែកមួយមិនអាចផ្ដាច់បានរបស់កិច្ចព្រមព្រៀង និង មានប្រសិទ្ធិភាពដូចកិច្ចព្រមព្រៀងដែរ ។

**ប្រការ១៥ :** ១- កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាព ១៥ ថ្ងៃ បន្ទាប់ពីថ្ងៃចុះហត្ថលេខា នឹងមានតំលៃសំរាប់ រយៈពេល ២ ឆ្នាំ ។ប្រសិនបើក្នុងរយៈពេល ០៣ ខែ មុនពេលកិច្ចព្រមព្រៀងអស់សុពលភាពពុំមានភាគីណាមួយនៃភាគីទាំងពីរមានសំណើ ជាលាយលក្ខណ៍អក្សរដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះទេ កិច្ចព្រមព្រៀងនេះ នឹងត្រូវបន្តដោយស្វ័យប្រវត្តិសំរាប់រយៈពេល ០១ ឆ្នាំទៀត ។

២- នៅពេលកិច្ចព្រមព្រៀងនេះផុតសុពលភាព ប្រការទាំងឡាយ នៃកិច្ចព្រមព្រៀងនេះនៅតែត្រូវបានអនុវត្តសំរាប់កិច្ចសន្យានានា ដែលបានចុះហត្ថលេខា មុនពេលបញ្ចប់សុពលភាព នៃ កិច្ចព្រមព្រៀងនេះ រហូតដល់ពេលអនុវត្តចប់សព្វគ្រប់ជាស្ថាពរ ។

៣- ដើម្បីជាសក្ខីភាព អ្នកចុះហត្ថលេខាខាងក្រោម ដែលបានទទួលសិទ្ធិប្រទានពីរដ្ឋាភិបាល រៀង១ខ្លួនយ៉ាងពិតប្រាកដ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០១ ជាពីរច្បាប់ដើមជាភាសាខ្មែរ វៀតណាម និង ភាសាអង់គ្លេស ដែលមានតំលៃអនុវត្តដូចគ្នា ។ ក្នុងករណីមាន ការបកស្រាយខុសគ្នា ច្បាប់ជាភាសាអង់គ្លេស ត្រូវយកមកប្រើប្រាស់ជាច្បាប់គោល ។

| | |
|---|---|
| **ជូនមុខរាជរដ្ឋាភិបាលនៃ** | **ជូនមុខរដ្ឋាភិបាលនៃ** |
| **ព្រះរាជាណាចក្រកម្ពុជា** | **សាធារណរដ្ឋសង្គមនិយមវៀតណាម** |
| **ចម ប្រសិទ្ធ** | **ម៉ៃ វ៉ាន់ យ៉ឺវ** |
| **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** | **អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** |

## ឧបសម្ព័ន្ធ ០១

## បញ្ជីរាយមុខទំនិញហាមនាំចេញ និងនាំចូល របស់កម្ពុជា

### I. ទំនិញហាមនាំចេញ

១- គ្រឿងសព្វាវុធ សំភារៈជាតិផ្ទុះ សំភារៈបរិក្ខាយោធា ។

២- គ្រឿងញៀន គ្រប់ប្រភេទ

៣- ត្បូងមានតំលៃ : មាសឆៅ ត្បូងមិនទាន់កែឆ្នៃ ឬ វត្ថុធាតុដើមត្បូងមិនទាន់កែឆ្នៃ ដែលជាកម្មវត្ថុ ដែលបានកំណត់ដោយប្រកាសរបស់ធនាគារកណ្តាល បើសិនជាមានតំលៃស្មើ ឬលើសពី មួយម៉ឺនដុល្លាអាមេរិក។

៤- ផលិតផលព្រៃឈើ :

- ឈើមូល ទោះបកសំបក ឬទាំងសំបក
- ឈើអារសុទ្ធសាធ
- ឈើជ្រុងដែលមានកំរាស់ លើសពី ២៥ស.ម ទោះបីបានឈូសក៏ដោយ
- អុសគ្រប់ប្រភេទ ទោះបីចង់ជាបាច់ក៏ដោយ
- ធ្យូងឈើ

### II. ទំនិញហាមនាំចូល

១- គ្រឿងសព្វាវុធ សំភារៈជាតិផ្ទុះ សំភារៈបរិក្ខាយោធា

២- គ្រឿងញៀន គ្រប់ប្រភេទ

៣- ត្បូងមានតំលៃ : មាសឆៅ ត្បូងមិនទាន់កែឆ្នៃ ឬ វត្ថុធាតុដើមត្បូងមិនទាន់កែឆ្នៃ ដែលជាកម្មវត្ថុ ដែលបានកំណត់ដោយប្រកាសរបស់ធនាគារកណ្តាល បើសិនជា មានតំលៃស្មើ ឬលើសពី មួយម៉ឺនដុល្លាអាមេរិក។

៤- ស្បែកជើងប្រើហើយ

## ឧបសម្ព័ន្ធ ០២

## បញ្ជីរាយមុខទំនិញហាមនាំចេញ និងនាំចូល របស់វៀតណាម

### I. ទំនិញហាមនាំចេញ

១- គ្រឿងសញ្ញាវុធ គ្រាប់រំសេវ ជាតិរំសេវ ជាតិផ្ទុះ សំភារៈបរិក្ខាបច្ចេកទេសយោធា ។

២- វត្ថុបុរាណ

៣- គ្រឿងញៀន គ្រប់ប្រភេទ

៤- ជាតិគីមីពុល

៥- ឈើមូល ឈើអារ កាប់ចេញពីព្រៃធម្មជាតិ ផលិតផល ផលិតផលពាក់កណ្ដាលសំរេច ធ្វើពីឈើ ព្រៃធម្មជាតិរបស់វៀតណាម

៦- សត្វព្រៃ រុក្ខជាតិ ធម្មជាតិ ដែលកម្ររកបាន និង មានតំលៃ ។

៧- បណ្ដាប្រភេទម៉ាស៊ីន សំរាប់ប្រើប្រាស់ពិសេសនិងរាល់កម្មវិធី **Software** ប្រើប្រាស់ក្នុងក្របខណ្ឌ ការពារការសំងាត់របស់រដ្ឋ ។

### II. ទំនិញហាមនាំចូល

១- គ្រឿងសញ្ញាវុធ គ្រាប់រំសេវ ជាតិរំសេវ ជាតិផ្ទុះ សំភារៈបរិក្ខាបច្ចេកទេសយោធា ។

២- គ្រឿងញៀន គ្រប់ប្រភេទ

៣- ជាតិគីមីពុល

៤- វប្បធម៌ពាលាអាវ៉ាសែ អាសអាភាស ប្រតិកិរិយាគ្រប់ប្រភេទ ។

៥- ផាវគ្រប់ប្រភេទ ប្រដាប់សំរាប់ក្មេងលេង ដែលជះឥទ្ធិពលអាក្រក់ ដល់ការអប់រំ ចរិយា និងសន្តិសុខសណ្ដាប់ធ្នាប់សង្គម ។

៦- បារី បារីស៊ីហ្គា និងបណ្ដាប្រភេទជាផលិតផលបារីជាសំរេច( លើកលែងបុគ្គលដែលយកតាមខ្លួនពេលធ្វើដំណើរដោយកំណត់ចំនួន )

៧- ទំនិញប្រើប្រាស់ចាស់ ៗ ( លើកលែងឥវ៉ាន់រួមដំណើរ ព្រមទាំងឥវ៉ាន់ ( ទំនិញ ) ជាសេចក្ដីត្រូវការរបស់បុគ្គលផ្នែកការបរទេស នៃបណ្ដាប្រទេស និងបណ្ដាអង្គការអន្តរជាតិ និងឥវ៉ាន់អ្នកដំណើរតាមការកំណត់ ) ។

៨- មធ្យោបាយដឹកជញ្ជូន រថយន្តចង្កូតស្ដាំប្រើប្រាស់រួច ព្រមទាំងដោះចេញជាបំណែក និងប្រភេទដូរចង្កូតមុន

ពេលនាំចូលវៀតណាម លើកលែងមធ្យោបាយពិសេស មានចង្កូតស្តាំ ដូចជា រថយន្តស្ទូច ម៉ាស៊ីនជីកព្រែក រថយន្តបោសសំអាតផ្លូវ រថយន្តដឹកសំរាមរថយន្តអ៊ុតថ្នល់រថយន្តដឹកអ្នកដំណើរក្នុងអាកាសយានដ្ឋាន រថយន្ត លើកទំនិញក្នុងឃ្លាំង និងក្នុងកំពង់ផែ ។

៩- សំភារៈមធ្យោបាយប្រើប្រាស់ចាស់ ៗ រួមមាន :

- ម៉ាស៊ីន តួ សំបកកង់ ពោះវៀន ម៉ូទ័រចាស់ៗរបស់រថយន្ត
- ម៉ាស៊ីនអូសកង់ពីរ និងកង់បី មានបំពាក់ម៉ាស៊ីន
- ម៉ូទ័រចាស់មានកំលាំងពី ៣០ CV ចុះ
- ម៉ាស៊ីនចាស់ៗដែលមានបំពាក់ម៉ូទ័រមានកំលាំងពី ៣០ CV ចុះ
- សាក់ស៊ីចាស់ ៗ មានបំពាក់ម៉ាស៊ីន
- កង់ចាស់ ៗ
- ទោចក្រយានយន្ត ត្រីចក្រយានយន្តចាស់ ៗ
- រថយន្តពេទ្យចាស់ ៗ
- រថយន្តចាស់ ៗដឹកអ្នកដំណើរពី ១៦ កៅអីចុះ
-រថយន្តដឹកអ្នកដំណើរ ១៦កៅអីឡើង ដែលប្រើប្រាស់រួចហើយ ហួស ៥ឆ្នាំ គិតពីឆ្នាំនាំចូល ។
-រថយន្តដឹកជញ្ជូនទំនិញមានទំងន់ពី ៥ តោន ចុះ ដែលប្រើប្រាស់រួចហើយ ហួស ៥ឆ្នាំ គិតពីឆ្នាំនាំចូល ។

១០- ផលិតផលសំភារៈមានជាតិ **Amiang** ស្ថិតក្នុងក្រុម **AMPHIBOLE**

១១- បណ្តាប្រភេទម៉ាស៊ីន សំរាប់ប្រើប្រាស់ពិសេសនិងរាល់កម្មវិធី **Software** ប្រើប្រាស់ក្នុងក្របខណ្ឌការពារការសំងាត់របស់រដ្ឋ ។